# របាយការណ៍អំពីការរីកចម្រើននៅសាលា

នេះជាការបន្ថែមថ្មីលើបញ្ជីឈ្មោះវិទ្យាល័យឆ្នាំនេះ ដែលមាននៅលើទំព័រ៦នៃបញ្ជីឈ្មោះនេះ។ ដើម្បីឲ្យបានយល់ច្បាស់នូវអ្វីៗដែលមាននៅក្នុងតារាងរៀបរាប់សង្ខេបនៅខាងស្តាំដៃផ្នែកខាងក្រោមនៃទំព័រសម្រាប់វិទ្យាល័យនីមួយៗ នៅក្នុងបញ្ជីឈ្មោះវិទ្យាល័យនេះ សូមប្រើឯកសារនេះជាឯកសារយោង។

របាយការណ៍អំពីការរីកចម្រើនរបស់សាលា (SPR) គឺជាវិធីថ្មី ដែលបានរៀបចំឡើងដើម្បីជួយយើងខ្ញុំ ក្នុងការជួយ ឆ្លើយតប និង កែលម្អ សាលារបស់យើង។ របាយការណ៍អំពីការរីកចម្រើនរបស់សាលា បង្ហាញឲ្យឃើញនូវជំនឿសំខាន់ៗរបស់យើង ថាសិស្សានុសិស្សរបស់យើងទាំងអស់គប្បីទៅរៀននៅសាលាល្អៗ ហើយយើងត្រូវតែប្រកាន់ជំហររបស់យើងសម្រាប់មូលដ្ឋាននៃឧត្តមភាពក្នុងការអប់រំ។ របាយការណ៍អំពីការរីកចម្រើននៅសាលា អាចឲ្យយើងដឹងថាតើយើងធ្វើបានតាមមូលដ្ឋាននេះឬអត់ និង អាចឲ្យយើងតាមដានការរីកចម្រើនដោយប្រៀបធៀបជាមួយនឹងគោលដៅដែលបានរៀបរាប់នៅក្នុងផែនការ v2.0 របស់ក្រសួង។

## លក្ខណៈពិសេស៖

- របាយការណ៍អំពីការរីកចម្រើនរបស់សាលា ពិនិត្យមើលសាលាពីចំណុចជាច្រើន ឆ្លុះបញ្ចាំង និង ឲ្យតម្លៃ ដល់ភាពសម្បូរ និង លក្ខណៈស្មុគស្មាញ នៃបទពិសោធន៍ក្នុងការអប់រំ។
- ក្នុងចំណោមវិស័យទាំងនេះ របាយការណ៍អំពីការរីកចម្រើនរបស់សាលា ផ្តោតធ្ងន់ទៅលើការរីកចម្រើនរបស់សិស្ស ឆ្លុះបញ្ចាំងអំពី ការយកចិត្តទុកដាក់ និង ការប្តេជ្ញាចិត្ត របស់យើង ដើម្បីធ្វើយ៉ាងណាឲ្យសិស្សានុសិស្សរបស់យើងទាំងអស់ រៀនសូត្រ។
- របាយការណ៍អំពីការរីកចម្រើនរបស់សាលា មានរួមបញ្ចូលការប្រៀបធៀបដែលមានប្រយោជន៍ រវាង «ក្រុមសិស្សានុសិស្ស» សាលាដែលបង្រៀនក្រុមសិស្សដែលស្រដៀងៗគ្នា។
- របាយការណ៍អំពីការរីកចម្រើនរបស់សាលា គឺជាវិធីគ្រប់គ្រងក្នុងតំបន់ ដែលបានរៀបចំឡើងឲ្យមាន យុត្តធម៌ និង អាចអនុវត្តទៅបាន។

## គោលបំណង និង ការអនុវត្ត៖

- ដើម្បី ឲ្យបានដឹង និង អបអរសាទរ ជ័យជំនះ
- ដើម្បីឲ្យបានដឹងពី សេចក្តីត្រូវការ ការធ្វើអន្តរាគមន៍ និង ការគាំទ្រ
- ដើម្បីធ្វើការសម្រេចចិត្តដោយផ្អែកទៅលើភស្តុតាង រួមទាំង ការធ្វើអន្តរាគមន៍ ការចម្លងតាម និង ការពង្រីក។
- ដើម្បីរៀបវិធីសាស្ត្រប្រើធនធានឲ្យមានឥទ្ធិពលល្អបំផុតដល់សិស្សានុសិស្ស
- ដើម្បីតាមដានការរីកចម្រើន ដោយប្រៀបធៀបជាមួយនឹងគោលដៅដែលបានរៀបរាប់នៅក្នុងផែនការ v2.0។

## ដំណាក់កាលនៃការអប់រំ៖

ការរីកចម្រើនរបស់សាលាតាមកម្រិត សរុប និង តាមប្រភេទ បានបែងចែកទៅជាកាលបួននៃការអប់រំ ដោយយោងទៅលើចំនួនភាគរយនៃពិន្ទុដែលរៀនបាន។

- សរុប/Overall៖ ពិន្ទុសរុបរបស់សាលា បង្ហាញពីលទ្ធផលរួមគ្នាលើ ជោគជ័យ ការរីកចម្រើន បរិយាកាស និង មហាវិទ្យាល័យ និង អាជីព (សម្រាប់តែវិទ្យាល័យតែប៉ុណ្ណោះ)។
- ជោគជ័យ/Achievement៖ ជោគជ័យ វាស់លទ្ធផលនៃការវាយតម្លៃទូទៅ រួមមាន ការប្រឡង DRA, PSSA, Keystone, និង ACCESS សម្រាប់សិស្ស ELLs។
- ការរីកចម្រើន/Progress៖ ការរីកចម្រើន វាស់ការរីកចម្រើនក្នុងការវាយតម្លៃទូទៅ និង ការរីកចម្រើនទៅកាន់ការបញ្ចប់ការសិក្សា (សម្រាប់តែវិទ្យាល័យតែប៉ុណ្ណោះ)។
- បរិយាកាស/Climate៖ បរិយាកាស វាស់ ការចូលរួមរបស់សិស្ស និង បរិយាកាសរបស់សាលា។
- មហាវិទ្យាល័យ និង អាជីព/College & Career៖ មហាវិទ្យាល័យ និង អាជីព វាស់ការត្រៀមខ្លួនជាស្រេចសម្រាប់ មហាវិទ្យាល័យ និង អាជីព និង លទ្ធផលក្រោយពីវិទ្យាល័យ។

ធ្វើអន្តរាគមន៍/Intervene
បានពិន្ទុពី ០-២៤% នៃពិន្ទុដែលអាចទទួល

តាមដាន/Watch
បានពិន្ទុពី ២៥-៤៩% នៃពិន្ទុដែលអាចទទួល

ពង្រឹង/Reinforce
បានពិន្ទុពី ៥០-៧៤% នៃពិន្ទុដែលអាចទទួល

គំរូ/Model
បានពិន្ទុពី ៧៥-១០០% នៃពិន្ទុដែលអាចទទួល

| | |
|---|---|
| **លំដាប់នៃលទ្ធផល SPR សរុប៖** | តាមដាន/WATCH |
| **SPR សរុប ដោយមិត្ត៖** | **ទី៥ នៃ ១២/5th of 12** |
| **លំដាប់នៃលទ្ធផល តាមប្រភេទ៖** | |
| ជោគជ័យ/Achievement៖ | ធ្វើអន្តរាគមន៍/INTERVENE |
| ការរីកចម្រើន/Progress៖ | តាមដាន/WATCH |
| បរិយាកាស/Climate៖ | គំរូ/MODEL |
| មហាវិទ្យាល័យ និង អាជីព/College & Career៖ | គំរូ/MODEL |

SAMPLE

ព័ត៌មានបន្ថែមមាននៅក្នុងវិបសៃ៖ http://webgui.phila.k12.pa.us/offices/s/strategic-analytics/annual-reports/school-progress-reports

បញ្ជីឈ្មោះវិទ្យាល័យនៃទីក្រុងហ្វីឡាដែលហ្វ្យា ការទទួលសិស្សនៅ ខែកញ្ញា ឆ្នាំ២០១៥